**Speech by Mr. HIROSE Atsushi**
**Second Secretary of the Embassy of Japan in the Kingdom of Cambodia**
**On the occasion of the Inauguration Ceremony of The Project for Road Improvement in Stueng Trang Commune, Sala Krau District, Pailin Province**
**23 April, 2019**

- Venerable Monks,
- H.E. Mr. Cheng Nhan, Vice-Governor of Pailin Province,
- Mr. Eat Sarath, Director of Pailin Provincial Department of Public Works and Transport,
- Distinguished Guests, Ladies and Gentlemen.

It is a great pleasure for me to attend today's ceremony, in the presence of H.E. Mr. Cheng Nhan, Vice-Governor of Pailin Province, to celebrate the completion of the Project for Road Improvement in Stueng Trang Commune, Sala Krau District, Pailin Province.

As building infrastructure has been a priority in Japan's development assistance for Cambodia, various projects to improve infrastructure have been implemented, including in rural areas. Now, I am pleased to see the road has been significantly improved by the Grant Assistance for Grassroots Human Security Projects.

I understand that this improved road would benefit nearly 5,500 people living in the region. It is also expected that it will provide the local people with easier access between villages in the commune and improve their access to the main road from the villages especially in the rainy season.

I sincerely hope that Pailin Provincial Department of Public Works and Transport will maintain the road in a proper manner so that the local residents could benefit for a long period of time.

Finally, I would like to express my sincere appreciation to all the people concerned who have contributed to the smooth implementation of the project. I strongly hope that this road will become a symbol of the friendship between the two countries and further strengthen the friendly relations between the Japanese and Cambodian people.

**Thank you very much.**

**សុន្ទរកថារបស់ លោក ហ៊ីរ៉ូសិ អានស្ទ័សិ**
**លេខាទី២ ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា**
**ថ្លែងក្នុងពិធីសម្ពោធដាក់អោយប្រើប្រាស់គម្រោងកែលម្អផ្លូវ ក្នុងឃុំស្ទឹងត្រង់ ស្រុកសាលាក្រៅ ខេត្តប៉ៃលិន**
ថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៩

- **សូមក្រាបថ្វាយបង្គំ ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ**
- **សូមគោរព ឯកឧត្តម ចេង ញ៉ាន់ អភិបាលរងខេត្តប៉ៃលិន**
- **សូមគោរព លោក អ៊ាត សារ៉ាត់ ប្រធានមន្ទីរសាធារណការ និងដឹកជញ្ជូនខេត្តព្រះវិហារ**
- **សូមគោរព អស់លោក លោកស្រី!**

ខ្ញុំសប្បាយចិត្តណាស់ ដែលបានមកចូលរួមក្នុងពិធីសម្ពោធផ្លូវក្នុងថ្ងៃនេះ ជាមួយវត្តមានរបស់ **ឯកឧត្តម ចេង ញ៉ាន់** អភិបាលរងខេត្តប៉ៃលិន ដើម្បីប្រារព្ធពិធីសម្ពោធដាក់ឲ្យប្រើប្រាស់ផ្លូវមួយខ្សែ ក្នុងឃុំស្ទឹងត្រង់ ស្រុកសាលាក្រៅ ខេត្តប៉ៃលិន។

ការកសាងហេដ្ឋារចនាសម្ព័ន្ធ គឺជាវិស័យអាទិភាពមួយក្នុងជំនួយអភិវឌ្ឍរបស់ជប៉ុនសម្រាប់កម្ពុជា ហើយជាក់ស្តែងគម្រោងកែលម្អហេដ្ឋារចនាសម្ព័ន្ធជាច្រើនត្រូវបានអនុវត្ត រួមទាំងនៅតាមទីជនបទផងដែរ។ ឥឡូវនេះ ខ្ញុំពិតជាសប្បាយរីករាយណាស់ ដែលបានឃើញផ្លូវនេះពិតជាត្រូវបានកែលម្អ ក្រោមជំនួយឥតសំណងសម្រាប់គម្រោងទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិ។

ខ្ញុំទទួលស្គាល់ថា ផ្លូវដែលត្រូវបានកែលម្អនេះនឹងផ្តល់អត្ថប្រយោជន៍ដល់ប្រជាជនប្រមាណជា ៥,៥00នាក់ ដែលរស់នៅក្នុងតំបន់នេះ។ យើងក៏រំពឹងថា គម្រោងនេះ នឹងផ្តល់ភាពងាយស្រួលជាងមុនដល់ប្រជាជនក្នុងការធ្វើដំណើរពីភូមិមួយទៅភូមិមួយនៅក្នុងឃុំ និងជួយសម្រួលដល់ការធ្វើដំណើរពីភូមិទៅកាន់ផ្លូវជាតិ ជាពិសេសក្នុងរដូវវស្សា។

ខ្ញុំសង្ឃឹមយ៉ាងអស់ពីចិត្តថា មន្ទីរសាធារណការ និងដឹកជញ្ជូនខេត្តប៉ៃលិន នឹងថែទាំផ្លូវនេះឲ្យបានល្អ ដើម្បីឲ្យប្រជាជនទាំងអស់អាចទទួលបានអត្ថប្រយោជន៍យូរអង្វែង។

ជាចុងក្រោយនេះ ខ្ញុំសូមសម្តែងការអរគុណយ៉ាងជ្រាលជ្រៅចំពោះលោក-អ្នកទាំងអស់ ដែលបានរួមចំណែកក្នុងការអនុវត្តគម្រោងនេះប្រព្រឹត្តទៅបានយ៉ាងរលូន។ ខ្ញុំសង្ឃឹមយ៉ាងមុតមាំថា ផ្លូវនេះនឹងក្លាយជានិមិត្តរូបនៃមិត្តភាពរវាងប្រទេសយើងទាំងពីរ និងជួយពង្រឹងនូវទំនាក់ទំនងមិត្តភាពរវាងប្រជាជនជប៉ុន និងប្រជាជនកម្ពុជាបន្ថែមទៀត៕

**សូមអរគុណ!**